**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ០៧-សរណន

# សារាចរណែនាំ
## ស្តីពី
## ការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ អនុលោមតាមមាត្រា៤៤ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ក្នុងនាមជាប្រទេសហត្ថលេខី កម្ពុជាមានកាតព្វកិច្ចធ្វើរបាយការណ៍លើកដំបូង២ឆ្នាំក្រោយពីការផ្តល់សច្ចាប័ន និងធ្វើរបាយការណ៍ទៀងទាត់រៀងរាល់៥ឆ្នាំម្តង ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ ជូនគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ។ នៅឆ្នាំ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់របាយការណ៍លើកទី១ ជូនគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ បន្ទាប់មក របាយការណ៍លើកទី២និងទី៣ត្រូវបានធ្វើគួបគ្នា ដែលជាលទ្ធផលនៃការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជាពីឆ្នាំ២០០០ដល់ឆ្នាំ២០០៧ ហើយបានផ្ញើជូនគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩។ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ រាជរដ្ឋាភិបាលបានទទួលកម្រងសំណួរចំនួន២៦ ពីគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ដើម្បីផ្តល់ព័ត៌មានបំពេញបន្ថែមលើរបាយការណ៍ជាតិលើកទី២និងទី៣នេះ។ របាយការណ៍ជាតិលើកទី២និងទី៣ ត្រូវបានគណៈប្រតិភូកម្ពុជាទៅចូលរួមការពារក្នុងសម័យប្រជុំលើកទី៥៧ របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១។ បន្ទាប់មកកម្ពុជាទទួលបាននូវអនុសាសន៍មួយចំនួនដែលជាការសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ដើម្បីឱ្យកម្ពុជាបន្តអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារឱ្យកាន់តែមានប្រសិទ្ធភាព។

ដើម្បីអនុវត្តអនុសាសន៍មួយចំនួន ដែលមានលក្ខណៈវិជ្ជមាននិងស្ថាបនារបស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិចំពោះព្រះរាជាណាចក្រកម្ពុជា និងដើម្បីជំរុញការអនុវត្តគោលនយោបាយជាតិចំពោះកុមារឱ្យទទួលបានជោគជ័យ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ÷

១. គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិត្រូវយកចិត្តទុកដាក់អនុវត្តអនុសាសន៍ដែលមានលក្ខណៈវិជ្ជមាន និងស្ថាបនារបស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ដោយដាក់បញ្ចូលអនុសាសន៍ដែលពាក់ព័ន្ធទៅនឹងភារកិច្ចរបស់ក្រសួង ស្ថាប័នសាមី និងអាជ្ញាធរថ្នាក់ក្រោមជាតិ និងត្រូវចាត់តាំងអនុវត្តដោយការទទួលខុសត្រូវខ្ពស់ មានផែនការ គោលដៅ សកម្មភាព និងពេលវេលាកំណត់ ដើម្បីសម្រេចភារកិច្ចក្នុងអនុសាសន៍។

២. គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ ត្រូវសហការជាមួយដៃគូអភិវឌ្ឍ អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ ដើម្បីជំរុញអនុវត្តអនុសាសន៍ដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចដៃគូអភិវឌ្ឍនិងអង្គការនានាឱ្យទទួលបានជោគជ័យ សំដៅជំរុញនិងលើកកម្ពស់ការអនុវត្តសិទ្ធិកុមារនៅកម្ពុជាឱ្យបានកាន់តែល្អប្រសើរឡើង ក្នុងគោលដៅធានានូវឧត្តមប្រយោជន៍របស់កុមារ។

៣. រាជរដ្ឋាភិបាលកម្ពុជាសូមអំពាវនាវដល់ដៃគូអភិវឌ្ឍ អង្គការជាតិ អង្គការអន្តរជាតិដែលពាក់ព័ន្ធទាំងអស់ ចូលរួមសហការនិងផ្តល់ការឧបត្ថម្ភគាំទ្រដល់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារគ្រប់ថ្នាក់និងក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ សំដៅជំរុញការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារឱ្យទទួលជោគជ័យថែមទៀតជាឧត្តមប្រយោជន៍នៃកុមារកម្ពុជា។

៤. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវសហការគ្នារៀបចំគម្រោងថវិកាសម្រាប់វិស័យកុមារ ទៅក្នុងផែនការថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ស្របតាមស្ថានភាពនៃថវិកាជាតិ។

៥. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវយកចិត្តទុកដាក់ធ្វើការផ្សព្វផ្សាយសារាចរណែនាំនេះ និងសហការជាមួយក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្នុងការចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធភាពនូវអនុសាសន៍ដែលស្របនឹងស្ថានភាពជាក់ស្តែងដែលកម្ពុជាអាចទទួលយកបាន និងត្រូវតាមដានធ្វើរបាយការណ៍ស្តីពីការអនុវត្តសារាចរណែនាំនេះជាប្រចាំជូនរាជរដ្ឋាភិបាល។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវបង្កើតក្រុមការងារចម្រុះដើម្បីរៀបចំរបាយការណ៍យោងតាមអនុសាសន៍នេះ ផ្ញើជូនគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិបានទាន់ពេលវេលា។

៦. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវធ្វើការបកស្រាយនិងបញ្ជាក់ឱ្យបានច្បាស់លាស់ នូវអនុសាសន៍ណាដែលកម្ពុជាបាននិងកំពុងអនុវត្ត តាំងពីមុនពេលទទួលបាននូវអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិឆ្នាំ២០១១ ទៅក្នុងរបាយការណ៍ជាតិលើកទី៤ និងទី៥ ដែលនឹងត្រូវផ្ញើជូនគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ តាមពេលវេលាដែលបានកំណត់។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីរាជធានី ខេត្ត ត្រូវរៀបចំចាត់តាំងអនុវត្តក្នុងស្មារតីទទួលខុសត្រូវនិងមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *គ្រប់ក្រសួង ស្ថាប័ន*
- *សាលារាជធានី ខេត្ត*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*